ទម្រង់ជំនួយគតិយុត្តិសម្រាប់ជនជាតិភាគតិច ក្នុងរឿងក្តីជួញដូរមនុស្ស៖

ការផ្តល់ប្រឹក្សាផ្នែកច្បាប់៖



អ្នកអនុវត្តជំនួយគតិយុត្តិណែនាំ ផ្តល់យោបល់ និងជួយរៀបចំឯកសារដែលពាក់ព័ន្ធនឹងវិវាទ ប្តឹងតវ៉ា និងបញ្ហាទាក់ទិនផ្លូវច្បាប់ ព្រមទាំងណែនាំ និងជួយភាគីនានាឲ្យធ្វើការផ្សះផ្សា ចរចា និងឯកភាពលើដំណោះស្រាយចំពោះករណីដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត។

ការចូលរួមក្នុងនីតិវិធី៖



ភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយគតិយុត្តិ ចូលរួមក្នុងនីតិវិធីតុលាការដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ អ្នកទទួលជំនួយគតិយុត្តិ នៅចំពោះមុខស្ថាប័ននីតិវិធីក្នុងករណីដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត។

តំណាងក្រៅនីតិវិធី៖



ភ្នាក់ងារជំនួយគតិយុត្តិ និងមេធាវីអនុវត្តជំនួយគតិយុត្តិ ជាតំណាង ឬតំណាងជំនួស អ្នកទទួលជំនួយគតិយុត្តិធ្វើការជាមួយស្ថាប័នរដ្ឋមានសមត្ថកិច្ច អំពីបញ្ហាដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត។

អស័យដ្ឋានទំនាក់ទំនង ដើម្បីស្នើសុំជំនួយគតិយុត្តិ ក្នុងករណីពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត

មជ្ឈមណ្ឌលជំនួយគតិយុត្តិរដ្ឋ ស្ថិតក្រោមមន្ទីរយុត្តិធម៌រាជធានី ខេត្ត និងក្រុងដែលស្ថិតក្រោមមជ្ឈឹម។

អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាផ្នែកច្បាប់ ដែលចូលរួមអនុវត្តជំនួយគតិយុត្តិ។

:អសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានប្រកាសជាសាធារណៈនៅ៖

- **គេហទំព័រនីតិកម្មជាតិ**
  https://phapluat.gov.vn/
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់ក្រសួងយុត្តិធម៌**
  https://dstrogiupphaply.moj.gov.vn/all/searchOrganization
- **គេហទំព័រព័ត៌មានអេឡិចត្រូនិកស្តីពីជំនួយគតិយុត្តិនៅប្រទេសវៀតណាម**
  https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់មន្ទីរយុត្តិធម៌នៅមូលដ្ឋាន**



លោកអ្នកអាចទាក់ទងតាមមធ្យោបាយខាងក្រោម ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖

ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីជំនួយគតិយុត្តិ

១៨០០១២៣៣

(Cước gọi miễn phí)

ទាញយកកម្មវិធីទូរស័ព្ទចល័តស្តីពីជំនួយគតិយុត្តិ

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ Android

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ iOS

BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិសម្រាប់ជនជាតិភាគតិចក្នុងការចុះបញ្ជីកំណើត

TRỢ GIÚP PHÁP LÝ



ជនជាតិភាគតិចដែលទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃពីរដ្ឋ រួមមាន៖

- អ្នកមានសគុណចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងក្របខណ្ឌគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានស្ថានភាពសេដ្ឋកិច្ច - សង្គមលំបាកជាពិសេស។
- អ្នកដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ក្នុងករណីជាអ្នកត្រូវចោទប្រកាន់ អ្នកត្រូវបានស្នើឲ្យប្តឹង អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកចុងចោទ ជនរងគ្រោះ សាក្សី អ្នកដែលកំពុងស្ថិតក្រោមការអនុវត្តវិធានការដោះស្រាយបង្វែរទិស និងជាទណ្ឌិតក្នុងនីតិវិធីព្រហ្មទណ្ឌ។
- អ្នកចុងចោទដែលស្ថិតក្នុងក្របខ័ណ្ឌគ្រួសារបៀតក្រីក្រ។
- អ្នករងគ្រោះអ្នកដែលកំពុងស្ថិតក្នុងដំណើរការកំណត់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ រួមដំណើរជាមួយ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីមួយក្នុងចំណោមករណីដូចខាងក្រោមនេះ មានការលំបាកអំពីហិរញ្ញវត្ថុ៖ i) ឪពុកបង្កើត ម្តាយបង្កើត ប្តី ប្រពន្ធ កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ក្នុងការចិញ្ចឹមបីបាច់យុទ្ធជនពលីកាលពីនៅតូច; ii) អ្នកដែលរងផលប៉ះពាល់ដោយសារធាតុពុលពណ៌ទឹកក្រូច; iii) មនុស្សចាស់; iv) ជនមានពិការភាព; v) ជនរងគ្រោះក្នុងករណីអំពើហិង្សាគ្រួសារ; vi) អ្នកជ្រាប HIV។

លក្ខខណ្ឌលំបាកអំពីហិរញ្ញវត្ថុរបស់អ្នកទទួលជំនួយគតិយុត្តិគឺជាមុខសញ្ញាស្ថិតក្នុងគ្រួសារបៀតក្រីក្រ ឬជាមុខសញ្ញាដែលកំពុងទទួលប្រាក់ឧបត្ថម្ភសង្គមប្រចាំខែ តាមបទប្បញ្ញត្តិនៃច្បាប់។

ការចុះបញ្ជីកំណើត

• សំបុត្រកំណើត គឺជាលិខិតផ្លូវការដែលចេញដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច ជូនបុគ្គលនៅពេលបានចុះបញ្ជីកំណើត។ ខ្លឹមសារនៃសំបុត្រកំណើត រួមមានព័ត៌មានមូលដ្ឋានអំពីបុគ្គល ស្របតាមបទប្បញ្ញត្តិនៃច្បាប់។

• សមត្ថកិច្ចចុះបញ្ជីកំណើត៖ គណៈកម្មាធិការប្រជាជនថ្នាក់ឃុំកន្លែងស្នាក់នៅរបស់ឪពុក ឬម្តាយ។

• ឯកសារសម្រាប់ចុះបញ្ជីកំណើត រួមមាន៖

(i) ពាក្យស្នើសុំចុះបញ្ជីកំណើតតាមគំរូ។

(ii) លិខិតបញ្ជាក់កំណើត ឬឯកសារជំនួសលិខិតបញ្ជាក់កំណើត។ ក្នុងករណីមិនមានលិខិតបញ្ជាក់កំណើត ត្រូវដាក់ជូនលិខិតបញ្ជាក់របស់សាក្សីអំពីការសម្រាលកូន។ ប្រសិនបើមិនមានសាក្សីទេ គឺត្រូវមានលិខិតធានាអះអាងអំពីការសម្រាលកូន។

(iii) លិខិតស្នាមសម្គាល់អត្តសញ្ញាណ ដើម្បីបញ្ជាក់អំពីសាច់ញាតិរបស់អ្នកទៅចុះបញ្ជីកំណើត គឺជាច្បាប់ដើមមួយក្នុងចំណោមលិខិតស្នាមដូចជា៖ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណពលរដ្ឋ អត្តសញ្ញាណប័ណ្ណ អត្តសញ្ញាណប័ណ្ណអេឡិចត្រូនិក វិញ្ញាបនបត្របញ្ជាក់អត្តសញ្ញាណប័ណ្ណ ឬលិខិតស្នាមផ្សេងទៀតដែលមានភ្ជាប់រូបថត និងព័ត៌មានផ្ទាល់ខ្លួនចេញដោយស្ថាប័នមានសមត្ថកិច្ច និងនៅមានសុពលភាពប្រើប្រាស់។

• រយៈពេលចុះបញ្ជីកំណើត៖ ឪពុក ឬម្តាយ មានកាតព្វកិច្ចចុះបញ្ជីកំណើតឲ្យកូន ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃកំណើតរបស់កូន។ ក្នុងករណីដែលឪពុក ឬម្តាយមិនអាចចុះបញ្ជីកំណើតឲ្យកូនបានទេ គឺជីតា ជីដូន ឬសាច់ញាតិផ្សេងទៀត ឬបុគ្គល អង្គការដែលកំពុងចិញ្ចឹមថែទាំកុមារ មានកាតព្វកិច្ចចុះបញ្ជីកំណើតឲ្យកុមារ។

• លើកលែងការបង់កម្រៃសេវាចុះបញ្ជីកំណើត សម្រាប់ពលរដ្ឋវៀតណាមដែលមានទីលំនៅនៅក្នុងប្រទេស។

(មាត្រា ៤ និងមាត្រា ១៦ នៃច្បាប់អត្រានុកូលដ្ឋាន។ មាត្រា ២ និងមាត្រា ៩ នៃអនុក្រឹត្យលេខ ១២៣/២០១៥/NĐ-CP បានវិសោធនកម្ម និងបំពេញបន្ថែមតាមមាត្រា ២ នៃអនុក្រឹត្យលេខ ០៧/២០២៥/NĐ-CP)៕

